ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ...២៦៧........... បទ-ប្រក.

"....ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

# ប្រកាស
# ស្តីពី
# ការតភ្ជាប់បណ្តាញទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ខែសីហាឆ្នាំ២០០២ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០៨ ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,

- បានឃើញគោលការណ៍និយ័តកម្មនៃវិស័យទូរគមនាគមន៍របស់អង្គការពាណិជ្ជកម្មពិភពលោក និង សហភាពទូរគមនាគមន៍អន្តរជាតិ,
- យោងប្រកាសលេខ ២៥៩ បទ.ប្រក ចុះថ្ងៃទី២៣ខែកក្កដាឆ្នាំ២០០៣ ស្តីពីការតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទ,
- យោងសេចក្តីសម្រេចលេខ ១៩៦ បទ.សសរ ចុះថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងាររបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីរៀបចំគោលនយោបាយថ្មីនៃការភ្ជាប់បណ្តាញនិងអាជីវកម្មទូរគមនាគមន៍,
- យោងសារាចរអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លេខ ១២៣៣ ស.ហ.វ. - ប.ទ. ចុះថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០០៩ ស្តីអំពីវិធានការទប់ស្កាត់ភាពពុំស្មោះត្រង់នៃការប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍,
- យោងសេចក្តីត្រូវការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

# សម្រេច

## ផ្នែកទី ១

## គោលការណ៍សម្រាប់ចរចាលើសមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍

### ប្រការ ១ : និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសទាំងឡាយក្នុងប្រកាសនេះមានដូចតទៅ៖

- **ការតភ្ជាប់បណ្តាញរវាងគ្នា** គឺជាការតភ្ជាប់ដោយរូបវន្ត និង ឡូស៊ីករវាងបណ្តាញទូរគមនាគមន៍ដែលតាមរយៈនោះអ្នកប្រើប្រាស់សេវាអាចទាក់ទងគ្នាពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀត។

- **សណ្ឋានៃការតភ្ជាប់បណ្តាញ** គឺជាបណ្តាញមួយដែលកើតឡើងពីការតភ្ជាប់គ្នានៃបមាណទូរស័ព្ទទាំងឡាយទៅនឹងមជ្ឈមណ្ឌលបមាណកណ្តាលមួយដោយមានសមត្ថភាព និង គុណភាពស្របទៅតាមការកំណត់របស់ក្រសួង

ប្រៃសណីយ៍និងទូរគមនាគមន៍។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជ្រើសរើសយកបណ្តាញនៃការតភ្ជាប់នោះជាសណ្ឋាន « ស្តារ » ( Star Topology )។

- ចំណុចតភ្ជាប់ ( Point Of Interconnection " POI " ) គឺជាចំណុចស្ថិតនៅលើផ្លូវតភ្ជាប់រវាងបមាណ័ទូរស័ព្ទពីរ មានចែករំលែកប្រទល់ទទួលខុសត្រូវលើសេដ្ឋកិច្ចបច្ចេកទេសរវាងបណ្តាញទូរគមនាគមន៍ និង ក្រុមហ៊ុនទាំងពីរ ។

- ទិសដៅតភ្ជាប់ ( Direction ) គឺជាខ្សែតភ្ជាប់រវាងបមាណ័ទូរស័ព្ទដែលចូលរួមការតភ្ជាប់ដោយរៀបជាក្រុមផ្លូវសម្រាប់ប្រើប្រាស់តាមកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់រវាងក្រុមហ៊ុនទាំងនោះ។

- ផ្លូវ E1 គឺជាផ្លូវ Digital បឋមមានល្បឿន 2048 Kb/s តាមនិយមន័យក្នុងឯកសារ ITU-G.701។

- ផ្លូវ STM-1 គឺជាផ្លូវ Digital បឋមមានល្បឿន 155.52 Mb/s តាមនិយមន័យក្នុងឯកសារ ITU-G.701។

- ថ្លៃជួលជារខែ ផ្លូវ E1 ក្នុងខេត្ត-ក្រុង គឺជាថ្លៃជួលជាប្រចាំខែនៃផ្លូវ E1 ក្នុងខេត្ត-ក្រុង ដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដាក់ឱ្យអនុវត្ត។

- ក្រុមហ៊ុនផ្តល់ការតភ្ជាប់ គឺជាក្រុមហ៊ុនមួយដែលក្រុមហ៊ុនមួយផ្សេងទៀតស្នើសុំតភ្ជាប់ជាមួយ។

- ក្រុមហ៊ុនសុំការតភ្ជាប់ គឺជាក្រុមហ៊ុនមួយស្នើទៅក្រុមហ៊ុនមួយផ្សេងទៀតសុំផ្តល់ការតភ្ជាប់។

- ការតភ្ជាប់ផ្ទៃក្នុង គឺជាការតភ្ជាប់បណ្តាញទូរគមនាគមន៍រវាងអង្គភាពផ្សេងៗក្រោមឱវាទក្រុមហ៊ុនតែមួយ។

- ការតភ្ជាប់ឆ្លងប្រព័ន្ធ គឺជាការតភ្ជាប់បណ្តាញទូរគមនាគមន៍រវាងក្រុមហ៊ុនពីរខុសគ្នា។

**ប្រការ ២ : គោលបំណង**

គោលបំណងនៃប្រកាសនេះ គឺដើម្បីៈ

- កំណត់សិទ្ធិនិងកាតព្វកិច្ចនៃប្រតិបត្តិករដែលកាន់អាជ្ញាប័ណ្ណ ឬ មាន

អនុញ្ញាតផ្តល់សេវាទូរគមនាគមន៍សម្រាប់ការតភ្ជាប់ទៅវិញទៅមកក្នុងព្រះរាជាណាចក្រកម្ពុជា។

- កំណត់ថេរវេលា ខ្លឹមសារ និងល័ក្ខខ័ណ្ឌសម្រាប់ការតភ្ជាប់ទៅវិញទៅមកនៃប្រតិបត្តិករដែលកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតផ្តល់សេវាទូរគមនាគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

- បង្កើតនីតិវិធីសម្រាប់ការចរចាលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

- បង្កើតនីតិវិធីសម្រាប់ដោះស្រាយវិវាទដែលទាក់ទងនឹងការចរចាលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

- ជំរុញឱ្យមានការប្រកួតប្រជែងក្នុងទីផ្សារទូរគមនាគមន៍នៅកម្ពុជាប្រកបដោយតម្លាភាព ស្មើភាពនិងស្មោះត្រង់។

- ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ថ្មី និង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព។

- បង្កើនសេវាទូរគមនាគមន៍ជូនសាធារណជនប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

## ប្រការ ៣ : វិសាលភាពអនុវត្ត

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិករកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតផ្តល់សេវាទូរគមនាគមន៍ជូនសាធារណជនក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤ : សិទ្ធិ និង ភាពចាំបាច់ក្នុងការតភ្ជាប់

អតិថិជនរបស់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍អាចភ្ជាប់ជាមួយអតិថិជនរបស់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍មួយផ្សេងទៀត ហើយក៏អាចប្រើប្រាស់សេវាដែលផ្តល់ដោយប្រតិបត្តិករទូរគមនាគមន៍ដទៃទៀតដែរ។

ប្រតិបត្តិករដែលកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតផ្តល់សេវាទូរគមនាគមន៍ត្រូវធានាឱ្យមានការតភ្ជាប់បណ្តាញជាមួយប្រតិបត្តិករទូរគមនាគមន៍ផ្សេងទៀតសម្រាប់អ្នកប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងនិងក្រៅប្រទេស។

ការតភ្ជាប់ត្រូវធានានូវរាល់ចំណុចតភ្ជាប់ណាដែលអាចធ្វើទៅបានតាមលក្ខណៈ

បច្ចេកទេសក្នុងបណ្តាញរបស់ប្រតិបត្តិករផ្តល់សេវា។ការតភ្ជាប់នៅចំណុចតភ្ជាប់ផ្សេងទៀតក្នុងបណ្តាញត្រូវផ្តល់តាមការស្នើសុំ ហើយថ្លៃតភ្ជាប់ត្រូវឆ្លុះបញ្ចាំងលើថ្លៃដើមនៃការសាងសង់និងការបំពាក់បន្ថែមនូវសម្ភារៈបរិក្ខារដែលចាំបាច់។

ការតភ្ជាប់ត្រូវផ្តល់ដោយៈ

- ពុំរើសអើងចំពោះថេរវេលា ល័ក្ខខ័ណ្ឌ ( បទដ្ឋាននិងលក្ខណៈបច្ចេកទេស ) និងអត្រាថ្លៃតភ្ជាប់ ហើយយ៉ាងហោចណាស់ត្រូវមានគុណភាពដូចសេវាដែលតភ្ជាប់ក្នុងបណ្តាញខ្លួន ឬ សេវាស្រដៀងគ្នានឹងសាខារបស់ខ្លួន។
- ទាន់ពេលវេលា។
- មានគោលការណ៍តម្លាភាព ថេរវេលា ល័ក្ខខ័ណ្ឌនិងអត្រាថ្លៃតភ្ជាប់ផ្អែកលើមូលដ្ឋានថ្លៃដើមដែលសមហេតុផល។
- ឈរលើគោលការណ៍គណនាថ្លៃដាច់ដោយឡែកពីគ្នា ដើម្បីចៀសវាងចំណាយលើសេវាមិនចាំបាច់។

ប្រតិបត្តិករផ្តល់ការតភ្ជាប់ត្រូវថែរក្សាការតភ្ជាប់ និង ផ្តល់ការប្រើប្រាស់សេវាពាក់ព័ន្ធផ្សេងៗទៀតស្របតាមពាក្យស្នើសុំតភ្ជាប់។

**ប្រការ ៥ : កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់បណ្តាញ**

ពាក្យស្នើសុំតភ្ជាប់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីទម្រង់នៃការស្នើសុំតភ្ជាប់ កាលបរិច្ឆេទ និង ការប៉ាន់ស្មានចំណុះល្បឿននៃការតភ្ជាប់ដែលត្រូវការ។

ក្រុមហ៊ុនដែលកាន់អាជ្ញាប័ណ្ណផ្តល់សេវាទូរគមនាគមន៍ត្រូវចេញផ្សាយកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ជាសាធារណៈ។

ការចរចាពាណិជ្ជកម្មជាមធ្យោបាយសំខាន់ក្នុងការឈានដល់ចុះកិច្ចព្រមព្រៀងដែលទាក់ទងនឹងការតភ្ជាប់។ ភាគីទាំងអស់ត្រូវចរចាគ្នាដោយសុទ្ធចិត្ត និង ផ្អែកលើមូលដ្ឋានតាមពេលវេលាកំណត់ណាមួយ។

ការចរចាលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់គ្នាពុំត្រូវហួសពី ៣ ខែបន្ទាប់ពីបានដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករ ( ក្រុមហ៊ុន ) ផ្តល់ការតភ្ជាប់។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសិទ្ធិពុំយល់ព្រមពន្យារពេល ប្រសិនបើគ្មានពាក្យស្នើសុំពីភាគីចរចាក្នុងករណីជាក់លាក់ណាមួយនោះ។

ក្រុមហ៊ុនផ្តល់ការតភ្ជាប់និងក្រុមហ៊ុនដែលស្វែងរកការតភ្ជាប់ត្រូវផ្តល់ព័ត៌មានអំពីវិក្កយបត្រទូទាត់ការប្រើប្រាស់សេវាដែលពាក់ព័ន្ធទៅវិញទៅមកឱ្យបានទៀងទាត់។

កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវចែងអំពីខ្លឹមសារ និង ល័ក្ខខ័ណ្ឌរវាងភាគីដែលទាក់ទងនិងការតភ្ជាប់។ ខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ត្រូវមាន៖

- វិសាលភាព និង ភាពជាក់លាក់នៃការតភ្ជាប់របស់ប្រភេទសេវាកម្ម.
- លទ្ធភាពអាចប្រើប្រាស់សេវាកម្មផ្សេងៗ និង ទីកន្លែងទាំងអស់ ដែលចាំបាច់សម្រាប់ផ្តល់ការតភ្ជាប់.
- កម្រិតសេវាកម្ម និង ការថែរក្សាគុណភាពសេវាកម្មពីចុងម្ខាងទៅចុងម្ខាងទៀត.
- ការបង់ថ្លៃតភ្ជាប់ និង ថ្លៃប្រើប្រាស់.
- វិធីគិតវិក្កយបត្រ និង ការទូទាត់.
- របៀបរៀបរយ ការព្យាករ ការផ្តល់ព័ត៌មាន និង នីតិវិធីនៃការសាកល្បង.
- ការផ្តល់ចំណុះ ល្បឿនតភ្ជាប់នៅរាល់ចំណុចតភ្ជាប់ណាដែលបច្ចេកទេសអាចធ្វើទៅបាន.
- ការបញ្ជូនទិន្នន័យស៊ីញ៉ាល់ចាំបាច់ ដែលទាក់ទងទៅនឹងសេវាកម្ម.
- ការផ្តល់ព័ត៌មានទាក់ទងនឹងទំនើបកម្ម ឬ សនិទានកម្មប្រព័ន្ធ.
- លក្ខណៈពិសេសផ្នែកបច្ចេកទេស បទដ្ឋាន និង ការសាកល្បងអន្តរប្រតិបត្តិការ.
- ការគ្រប់គ្រងប្រព័ន្ធ ចរាចរសន្ទនា ថែទាំ និង វាស់ស្ទង់.
- ការរក្សាការសម្ងាត់នៃព័ត៌មាន.
- រយៈពេល វិធីចរចា និង ការពិនិត្យឡើងវិញ.
- វិធីដោះស្រាយវិវាទ។

គ្រប់ប្រតិបត្តិករទូរគមនាគមន៍ត្រូវរៀបចំកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ រួចដាក់ជូនបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ពិនិត្យសម្រេច។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវពិនិត្យសម្រេចលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ដែលប្រតិបត្តិករទូរគមនាគមន៍ដាក់ជូន។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចអនុម័តយល់ព្រម បដិសេធ ឬ កែប្រែកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ដែល រៀបចំឡើងដោយក្រុមហ៊ុន។ បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរក្សាបញ្ជីឈ្មោះនៃកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ដែលបានអនុម័តរួចហើយ។

មានតែបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទេ ទើបមានសិទ្ធិអនុម័តការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

**ប្រការ ៦ : មូលដ្ឋានកំណត់ថ្លៃតភ្ជាប់**

អត្រាថ្លៃដើមត្រូវកំណត់យកជាមូលដ្ឋានសម្រាប់គិតថ្លៃតភ្ជាប់ដែលបោះពុម្ពផ្សាយដោយបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ថ្លៃតភ្ជាប់ត្រូវមានតម្លាភាព និង ត្រូវបែងចែកឱ្យបានគ្រប់គ្រាន់ ដើម្បីធានាថាមានតែថ្លៃដើមសេវាកម្មដែលប្រើក្នុងការតភ្ជាប់ទេ ដែលត្រូវបញ្ចូលក្នុងការគិតថ្លៃ។

ភាគីនីមួយៗដែលពាក់ព័ន្ធនឹងសេវាតភ្ជាប់ ត្រូវទទួលខុសត្រូវចំពោះការចំណាយលើទីកន្លែងតភ្ជាប់ប្រព័ន្ធ គ្រប់គ្រងបណ្តាញនិងបមាណីទូរស័ព្ទ ដើម្បីទ្រទ្រង់ចំណុចតភ្ជាប់ ( Point Of Interconnection " POI " ) ហើយភាគីទាំងអស់ត្រូវចែកគ្នាចេញថ្លៃលើសមត្ថភាពរបស់បណ្តាញតភ្ជាប់។

**ប្រការ ៧ : លក្ខខ័ណ្ឌបច្ចេកទេស**

ក្រុមហ៊ុនស្វែងរកការតភ្ជាប់ ត្រូវផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ទាក់ទងនឹងចំណុចតភ្ជាប់ ដើម្បីឱ្យក្រុមហ៊ុនដែលផ្តល់ការតភ្ជាប់កំណត់លក្ខណៈបច្ចេកទេសចាំបាច់សម្រាប់ធ្វើការវិភាគថ្លៃដើមនៃការបង្កើតចំណុចតភ្ជាប់។

ក្រុមហ៊ុនផ្តល់ការតភ្ជាប់ត្រូវបង្កើតចំណុចតភ្ជាប់ឱ្យបានឆាប់ បន្ទាប់ពីមានការសម្រេចលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ ដោយពុំត្រូវលើស ៣០ ថ្ងៃឡើយ។

កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ ត្រូវកំណត់គុណភាពសេវាឱ្យស្របតាមការអនុវត្តតភ្ជាប់ជាក់ស្តែងដែលល្អ ហើយត្រូវផ្តល់មូលហេតុចំពោះការមិនបានបំពេញតាមកម្រិតគុណភាពសេវាទាំងនោះ។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវកំណត់គុណភាពសេវា ប្រសិនបើភាគីទាំងអស់មិនបានគោរពតាមកិច្ចព្រមព្រៀង។

ទិន្នន័យនៃការបញ្ជូនស៊ីញ៉ាល់ ( Signaling Data ) ចាំបាច់ត្រូវបញ្ជូនរវាងភាគីតភ្ជាប់ឱ្យស្របតាមបទដ្ឋានអន្តរជាតិនិងល័ក្ខខ័ណ្ឌតម្រូវទាំងអស់ ដែលចេញដោយបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្រុមហ៊ុនដែលមានបំណងផ្លាស់ប្តូរផែនការពាក់ព័ន្ធនឹងប្រព័ន្ធទូរគមនាគមន៍ត្រូវផ្តល់ព័ត៌មានយ៉ាងតិច ៦ ខែមុន ជូនភាគីតភ្ជាប់ផងទៃ ដើម្បីកុំឱ្យប៉ះពាល់សេវាទូរគមនាគមន៍របស់ភាគីតភ្ជាប់។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវទទួលបន្ទុកចេញវិក្កយបត្រទូទាត់ថ្លៃសេវាដែលបានប្រើប្រាស់ជូនអតិថិជនរបស់ខ្លួន។

**ប្រការ ៨ : ការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់**

ការផ្អាក ឬ បញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ពុំអាចធ្វើទៅបានទេ ប្រសិនបើគ្មានការយល់ព្រមពីបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាមុន។

ក្រុមហ៊ុនផ្តល់ការតភ្ជាប់អាចបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ តែក្នុងករណីមានការរំលោភលើកិច្ចព្រមព្រៀង និង ក្នុងករណីដូចខាងក្រោម៖

- ក្រុមហ៊ុនផ្តល់ការតភ្ជាប់ បានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនអំពីគោលបំណងចង់បញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់,
- ក្រុមហ៊ុនស្វែងរកការតភ្ជាប់បានផ្តល់ឱកាស ដើម្បីដោះស្រាយបញ្ហាក្នុងការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់,
- ក្រុមហ៊ុនផ្តល់ការតភ្ជាប់បានទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរពីបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ ពុំត្រូវអនុញ្ញាតឱ្យមានការផ្អាក ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមកទេ លើកលែងតែក្នុងករណីចាំបាច់ដែលត្រូវបញ្ជាក់អំពីការកាត់បន្ថយសម្ភារៈនៃប្រព័ន្ធសេវាទូរគមនាគមន៍ ឬ ក្នុងករណីមានការគំរាមកំហែងចំពោះសម្ភារៈថែរក្សាការតភ្ជាប់។

## ប្រការ ៩ : ការដោះស្រាយវិវាទ

១ ) កម្មវត្ថុវិវាទនៃសមត្ថភាពតភ្ជាប់បណ្តាញ

ក ) ផែនការសមត្ថភាពតភ្ជាប់,

ខ ) ការចុះកិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់,

គ ) ការកែប្រែផ្លាស់ប្តូរផែនការសមត្ថភាពតភ្ជាប់,

ឃ ) ការពង្រីកសមត្ថភាពតភ្ជាប់,

ង ) បញ្ហាផ្សេងៗនៅពេលអនុវត្តកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

២ ) នីតិវិធីនៃការដោះស្រាយវិវាទ

ក ) ឯកសារស្នើសុំដោះស្រាយវិវាទ ដែលត្រូវផ្ញើមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍រួមមាន៖

- ឯកសារស្នើសុំដោះស្រាយវិវាទ,
- ឯកសារសេដ្ឋកិច្ច បច្ចេកទេស និង ភស្តុតាងដែលពាក់ព័ន្ធ,
- សំណូមពរ ( បើមាន )។

ខ ) អាសយដ្ឋានទទួលឯកសារដោះស្រាយវិវាទ :

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ កាច់ជ្រុងផ្លូវលេខ១១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ :

◎ ទូរស័ព្ទលេខ ០១២ ៧០ ៧១ ៧២, ០១៦ ៧០ ៧១ ៧២

◎ ទូរសារលេខ ០២៣ ៧២ ២៩ ៨១

◎ E-mail : soksamnang78@hotmail.com។

គ ) នីតិវិធីដោះស្រាយវិវាទ

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សម្រេចទទួលដោះស្រាយ ឬ ពុំដោះស្រាយវិវាទក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលឯកសារតវ៉ាដែលស្របច្បាប់។
- ក្នុងករណីកម្មវត្ថុដែលលើកឡើងនៅក្នុងឯកសារមិនស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវធ្វើលិខិតឆ្លើយតបជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់-លាស់អំពីមូលហេតុនិងធ្វើការណែនាំ ប្រសិនបើមាន។
- ក្នុងករណីសម្រេចទទួលដោះស្រាយវិវាទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវដោះស្រាយជាជំហានៗដូចតទៅៈ

ជំហានទី ១

ពិនិត្យមើលភាពស្របច្បាប់នៃខ្លឹមសារទាំងឡាយក្នុងសំណុំឯកសារ។ ក្នុងករណីចាំបាច់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបង្កើតក្រុមបេសកកម្មចុះពិនិត្យលើកម្មវត្ថុវិវាទនិងវាស់វែងតាមជាក់ស្តែង ដើម្បីវាយតម្លៃ រួចកំណត់មូលហេតុសំដៅទៅដោះស្រាយវិវាទលើការតភ្ជាប់។

ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងការតភ្ជាប់ត្រូវផ្តល់ទិន្នន័យគ្រប់គ្រាន់និងទាន់ពេលវេលា ផ្តល់ឧបករណ៍ ព្រមទាំងចាត់អ្នកឯកទេសឱ្យចូលរួមជាមួយក្រុមត្រួតពិនិត្យ ប្រសិនបើមានការស្នើសុំ។

ជំហានទី ២

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវធ្វើការសម្របសម្រួលការចរចាជាមួយភាគីពាក់ព័ន្ធ។

ជំហានទី ៣

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ចេញសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចដោះស្រាយវិវាទ។

## ជំហានទី ៤

ក្រុមហ៊ុនត្រូវអនុវត្តតាមខ្លឹមសារទាំងឡាយដែលមានចែងនៅក្នុងសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចដោះស្រាយវិវាទ។

ឃ ) ក្នុងករណីក្រុមហ៊ុនពុំឯកភាពចំពោះខ្លឹមសារក្នុងសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទេ ក្រុមហ៊ុននោះអាចធ្វើពាក្យស្នើសុំដោះស្រាយវិវាទបន្តទៅរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីពិនិត្យ ដោះស្រាយឡើងវិញ។ នៅចន្លោះពេលធ្វើពាក្យស្នើសុំដោះស្រាយវិវាទបន្តទៅទៀត និង រង់ចាំលទ្ធផលដោះស្រាយថ្មី ភាគីទាំងនោះត្រូវអនុវត្តតាមសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បណ្តោះអាសន្នសិន។

ភាគីណាមួយដែលធ្វើការចរចាលើកិច្ចព្រមព្រៀងអាចស្នើបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យធ្វើការស៊ើបអង្កេត និង ធ្វើការសម្រេច ដើម្បីដោះស្រាយវិវាទ។ ពាក្យស្នើសុំដាក់ជូនបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវទទួលយកពាក្យស្នើសុំអន្តរាគមន៍ដោយផ្អែកលើមូលដ្ឋានព័ត៌មានដើម្បីដោះស្រាយវិវាទ ព្រោះថាវិវាទនឹងពុំអាចដោះស្រាយបានទេ ប្រសិនបើគ្មានអន្តរាគមន៍ពីសំណាក់បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចស្នើភាគីទាំងអស់ឱ្យបន្តការចរចាដោយសុទ្ធចិត្ត ដើម្បីស្វែងរកដំណោះស្រាយ។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវអនុវត្តតាមនីតិវិធីដែលបានបោះពុម្ពផ្សាយរួចហើយអំពីការដោះស្រាយវិវាទនៅពេលធ្វើអន្តរាគមន៍។

ភាគីទាំងអស់ត្រូវទទួលខុសត្រូវក្នុងការបង្ហាញភាពពិតតាមរយៈពាក្យស្នើសុំអន្តរាគមន៍ជាលាយលក្ខណ៍អក្សរដើម្បីគាំទ្រការទាមទាររបស់ខ្លួន។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវសម្រេចដោះស្រាយវិវាទដោយផ្អែកលើភស្តុតាងដែលភាគីទាំងអស់បានប្រគល់ជូន ហើយត្រូវជម្រាបភាគីទាំងនោះវិញ មិនឱ្យលើសពី ៦០ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំជាលាយលក្ខណ៍អក្សរចុងក្រោយពីភាគីវិវាទ។

លក្ខខណ្ឌនៃដំណោះស្រាយវិវាទរបស់បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់អំពីមូលហេតុឱ្យសមហេតុផល។

# ផ្នែកទី ២

## និតិវិធីនៃការចរចាអំពីសមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍

### ប្រការ ១០ : ទំហំ និង កម្មវត្ថុនៃការអនុវត្ត

១) កំណត់អំពីការអនុវត្តការតភ្ជាប់បណ្តាញសំដៅជានាទូវចំណុះ ល្បឿន គុណភាព និង ថេរវេលាតភ្ជាប់ ( ហៅកាត់ថា ការជាជាសមត្ថភាពតភ្ជាប់ )។

២) ត្រូវអនុវត្តចំពោះរាល់ការចាត់ចែងលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់រវាងបណ្តាញទូរគមនាគមន៍សាធារណៈដូចខាងក្រោមៈ

- បណ្តាញទូរគមនាគមន៍អចល័ត ( ខេត្ត-ក្រុង ផ្លូវឆ្ងាយឆ្លងខេត្ត ឬ តំបន់ និងក្រៅប្រទេស ),
- បណ្តាញទូរគមនាគមន៍ចល័ត ( ទូទាំងប្រទេស និង ក្រៅប្រទេស )។

៣) មុខសញ្ញាត្រូវអនុវត្ត : គ្រប់ក្រុមហ៊ុនកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

### ប្រការ ១១ : គោលការណ៍នៃការតភ្ជាប់បណ្តាញរវាងគ្នា

១) ក្រុមហ៊ុនទូរគមនាគមន៍ត្រូវទទួលខុសត្រូវលើការកសាងផែនការ និងស្ថាបនាបណ្តាញទូរគមនាគមន៍ដោយមានប្រព័ន្ធត្រៀមបម្រុង សម្រាប់ធានាឆ្លើយតបនូវសមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍សាធារណៈឱ្យបានគ្រប់គ្រាន់

ស្របតាមផែនការមេស្តីពីការអភិវឌ្ឍបណ្តាញនិងសេវាទូរគមនាគមន៍ ហើយទទួលខុសត្រូវលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

២) ដោយអនុលោមតាមបទប្បញ្ញត្តិ និង ផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនទូរគមនាគមន៍ បន្ទាប់ពីចុះបញ្ជីនៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រៀងរាល់ឆ្នាំក្រុមហ៊ុនត្រូវចរចាគ្នា និង ចុះកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍សាធារណៈ ( ហៅកាត់ថា កិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់ ) សម្រាប់អនុវត្តការតភ្ជាប់បណ្តាញ និង ផ្តល់សេវាទូរគមនាគមន៍នៅឆ្នាំបន្ទាប់។

៣) នៅពេលអនុវត្តការតភ្ជាប់បណ្តាញទូរគមនាគមន៍សាធារណៈ ក្រុមហ៊ុនទូរគមនាគមន៍ត្រូវទទួលខុសត្រូវធានានូវសមត្ថភាពតភ្ជាប់ទៅតាមផែនការដែលបានព្រមព្រៀងគ្នា ហើយធានាពុំរើសអើងការតភ្ជាប់ផ្អែកក្នុងនិងក្នុងប្រព័ន្ធឡើយ។

៤) របាយការណ៍និងការដោះស្រាយវិវាទនៃការតភ្ជាប់រវាងក្រុមហ៊ុនដែលចូលរួមការតភ្ជាប់ ត្រូវអនុវត្តតាមប្រកាសនេះ និង ប្រកាសពាក់ព័ន្ធផ្សេងៗទៀត។

**ប្រការ ១២ : ផែនការសមត្ថភាពតភ្ជាប់បណ្តាញរវាងគ្នា**

រៀងរាល់ឆ្នាំក្រុមហ៊ុនដែលស្នើសុំការតភ្ជាប់ត្រូវរៀបចំផែនការសមត្ថភាពតភ្ជាប់របស់ខ្លួនសម្រាប់មួយឆ្នាំបន្ទាប់ ហើយត្រូវផ្ញើទៅក្រុមហ៊ុនផ្តល់ការតភ្ជាប់ មុនថ្ងៃទី៣១ខែធ្នូ រៀងរាល់ឆ្នាំ ដើម្បីឱ្យក្រុមហ៊ុនផ្តល់ការតភ្ជាប់មានមូលដ្ឋានធ្វើផែនការវិនិយោគបម្រើការងារតភ្ជាប់។ នៅក្នុងផែនការសមត្ថភាពតភ្ជាប់ប្រចាំឆ្នាំត្រូវបញ្ជាក់ច្បាស់អំពីពេលវេលា សមត្ថភាពប្រើប្រាស់ដោយលម្អិតតាមខែ ត្រីមាសចំពោះទិសដៅតភ្ជាប់នីមួយៗ និង ទីតាំងតភ្ជាប់។

ចំពោះវិធីសាស្ត្រគណនាសមត្ថភាពសរុបនៃការតភ្ជាប់មានកំណត់នៅក្នុងឧបសម្ព័ន្ធទី ៥។

**ប្រការ ១៣ : កិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់បណ្តាញរវាងគ្នា**

១) កិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់តម្រូវឱ្យក្រុមហ៊ុនពីរចរចាគ្នា និង ចុះកិច្ចព្រមព្រៀងរៀងរាល់ឆ្នាំតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីកិច្ចសន្យា។ កិច្ចសន្យានេះជាមូលដ្ឋានសម្រាប់អនុវត្តការតភ្ជាប់បណ្តាញទូរគមនាគមន៍រវាងក្រុមហ៊ុនពីរ។ ក្រៅពី

ឯកសារដែលមានចែងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីកិច្ចសន្យា ក៏ត្រូវមានចែងអំពីឯកសារផ្សេងៗទៀតដូចជា ផែនការផ្តល់សមត្ថភាពតភ្ជាប់ បែបបទបច្ចេកទេស បទដ្ឋានឯកទេស និង ទិដ្ឋភាពសេដ្ឋកិច្ចដើម្បីអនុវត្តផែនការ។

២ ) គោលការណ៍ចុះកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ ៖

- ការធានានូវសមត្ថភាពតភ្ជាប់ អាស្រ័យទៅនឹងការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តរវាងក្រុមហ៊ុនចូលរួម ឈរលើមូលដ្ឋានធានានូវគោលការណ៍តភ្ជាប់បណ្តាញដូចឯកសារប្រការ ៣ នៃប្រកាសនេះ។
- ក្នុងករណីក្រុមហ៊ុនពុំអាចព្រមព្រៀងគ្នាលើការតភ្ជាប់បណ្តាញទេ ត្រូវអនុវត្តតាមប្រការ ៤, ៥ , ៦, ៧ និង ៨ នៃប្រកាសនេះ ដើម្បីចុះកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់។

៣ ) លើមូលដ្ឋានផែនការសមត្ថភាពតភ្ជាប់ដែលបានព្រមព្រៀងគ្នា ក្រុមហ៊ុនត្រូវចុះកិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់ ហើយជាមួយគ្នានោះត្រូវផ្ញើរបាយការណ៍មកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីពិនិត្យ តាមដានការអនុវត្តសកម្មភាពតភ្ជាប់របស់ក្រុមហ៊ុន។ ការចុះកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ ត្រូវធ្វើឡើងមុនថ្ងៃទី៣១ខែឧសភា រៀងរាល់ឆ្នាំ។

៤ ) ការកែប្រែផ្លាស់ប្តូរផែនការក្នុងកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ត្រូវធ្វើឡើង តែមួយដងគត់ មុនថ្ងៃទី៣១ខែវិច្ឆិកា រៀងរាល់ឆ្នាំសម្រាប់ផែនការឆ្នាំបន្ទាប់។ ការកែប្រែផ្លាស់ប្តូរនេះ ត្រូវចាត់ទុកជាឧបសម្ព័ន្ធនៃកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់។ កម្រិតកែប្រែផ្លាស់ប្តូរសមត្ថភាពតភ្ជាប់អនុញ្ញាតតែក្នុងរង្វង់ ៣០ ភាគរយ ធៀបទៅ នឹងផែនការក្នុងកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់។ ក្នុងករណីក្រុមហ៊ុនសុំការតភ្ជាប់ កែប្រែផ្លាស់ប្តូរសមត្ថភាពលើសពី ៣០ ភាគរយធៀបទៅនឹងផែនការក្នុងកិច្ចសន្យាស្តីពីការលើចំណុចតភ្ជាប់នីមួយៗ ក្រុមហ៊ុនផ្តល់ការតភ្ជាប់មានសិទ្ធិស្នើទៅក្រុមហ៊ុនសុំការតភ្ជាប់ទូទាត់ចំណាយបន្ថែមចំពោះការកែប្រែនោះ។ កម្រិតចំណាយអតិបរមាពុំ ត្រូវលើសពីមួយដងលើថ្លៃជួលជាប្រចាំខែនៃផ្លូវ E1 ក្នុងខេត្ត-ក្រុង ចំពោះតែផ្លូវ E1 ដែលមានការកែប្រែក្រៅពី ៣០ ភាគរយនៃផែនការ។

ប្រការ ១៤ : ការធានាសមត្ថភាពតភ្ជាប់បណ្តាញរវាងគ្នាទៅតាមផែនការ

១ ) នៅពេលអនុវត្ត ប្រសិនបើក្រុមហ៊ុនសុំការតភ្ជាប់ស្នើសុំពង្រីកសមត្ថភាពតភ្ជាប់ទៅតាមផែនការប្រចាំខែ និង តាមចំណុចតភ្ជាប់នីមួយៗដែលមានចែងក្នុងកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ ក្រុមហ៊ុនផ្តល់ការតភ្ជាប់ត្រូវធានាតភ្ជាប់ភ្លាមៗ។

២ ) ការបង់ប្រាក់ធានាសម្រាប់ការសុំពង្រីកសមត្ថភាពនៃការតភ្ជាប់ :

- ក្រុមហ៊ុនផ្តល់ការតភ្ជាប់ត្រូវស្នើទៅក្រុមហ៊ុនសុំការតភ្ជាប់ឱ្យបង់ប្រាក់ធានាមួយខែក្នុងចំនួនទឹកប្រាក់មួយត្រីមាសនៃថ្លៃជួលជាវចំពោះផ្លូវ E1 ក្នុងខេត្ត-ក្រុងដែលប្រើប្រាស់ប្រចាំខែ។ ក្រុមហ៊ុនសុំការតភ្ជាប់ ត្រូវបង់ប្រាក់ធានាជូនក្រុមហ៊ុនផ្តល់ការតភ្ជាប់ ១៥ ថ្ងៃមុននៃខែដំបូង ក្នុងត្រីមាសនីមួយៗ។
- ប្រាក់ធានានឹងត្រូវរំលស់បណ្តើរៗទៅជាប្រាក់ថ្លៃតភ្ជាប់ ដែលក្រុមហ៊ុនសុំការតភ្ជាប់ ត្រូវបង់ជូនក្រុមហ៊ុនផ្តល់ការតភ្ជាប់នៅខែបន្ទាប់ ។
- ក្នុងករណីក្រុមហ៊ុនផ្តល់ការតភ្ជាប់ពុំផ្តល់ទាន់ពេលនូវសមត្ថភាពតភ្ជាប់តាមខែដូចក្នុងកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ទេ ក្រុមហ៊ុនផ្តល់ការតភ្ជាប់ត្រូវសងប្រាក់ធានាទៅក្រុមហ៊ុនសុំការតភ្ជាប់វិញ និងប្រាក់មួយចំនួនបន្ថែមស្មើនឹងប្រាក់ធានា។ ក្រៅពីនេះត្រូវបង់ប្រាក់ផាកពិន័យថែមទៀត ដោយសារតែបំពានលើកិច្ចសន្យា។

៣ ) ការផាកពិន័យលើការរំលោភបំពានកិច្ចសន្យា :

ក្នុងករណីក្រុមហ៊ុនផ្តល់ការតភ្ជាប់ពុំផ្តល់ទាន់ពេលវេលានូវសមត្ថភាពតភ្ជាប់តាមខែដូចក្នុងកិច្ចសន្យា ក្រុមហ៊ុនសុំការតភ្ជាប់មានសិទ្ធិផាកពិន័យក្រុមហ៊ុនផ្តល់ការតភ្ជាប់ចំពោះការរំលោភបំពានកិច្ចសន្យា។ កម្រិតអតិបរមានៃប្រាក់ពិន័យមិនត្រូវលើសថ្លៃជួលជាវផ្លូវ E1 ក្នុងខេត្ត-ក្រុង ចំពោះផ្លូវដែលមិនផ្តល់ទាន់ពេលតែប៉ុណ្ណោះ។

៤ ) នៅពេលអនុវត្តការធានាពង្រីកសមត្ថភាពតភ្ជាប់ទៅតាមកិច្ចសន្យា យោងលើ ឧបសម្ព័ន្ធទី ២ បើពិនិត្យឃើញថា ទិសដៅតភ្ជាប់ប្រើប្រាស់ពុំមានប្រសិទ្ធភាព

ទេ ក្រុមហ៊ុនផ្តល់ការតភ្ជាប់មានសិទ្ធិស្នើទៅក្រុមហ៊ុនសុំការតភ្ជាប់ឱ្យប្រមូលចំនួនផ្លូវដែលនៅសល់មកវិញ ដើម្បីធានាការប្រើប្រាស់ឱ្យមានប្រសិទ្ធភាព។ ការប្រមូលផ្លូវនៅសល់ អាចអនុវត្តបានប្រសិនបើមានឯកភាពរវាងគូភាគីទាំងពីរ។

ក្រុមហ៊ុនសុំការតភ្ជាប់មានសិទ្ធិរក្សាទុកបន្តទៅទៀតនូវសមត្ថភាពផ្លូវដែលនៅសល់ ដោយត្រូវបង់បន្ថែមប្រាក់ប្រចាំខែជូនក្រុមហ៊ុនផ្តល់ការតភ្ជាប់។ ក្រៅពីថ្លៃតភ្ជាប់នៅមានប្រាក់មួយចំនួនទៀតដែលកម្រិតអតិបរមានៃប្រាក់នេះ ពុំត្រូវលើសពីថ្លៃជួលជាប្រចាំខែផ្លូវ E1 ក្នុងខេត្ត-ក្រុង ចំពោះផ្លូវដែលនៅសល់។

**ប្រការ ១៥ : ការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់បណ្តាញរវាងគ្នា**

១) ក្រុមហ៊ុនសុំការតភ្ជាប់ អាចស្នើពង្រីកបន្ថែមសមត្ថភាពតភ្ជាប់ដោយថាហេតុទោះការពង្រីកបន្ថែមនោះពុំស្ថិតក្នុងផែនការខែគិតទៅតាមចំណុចតភ្ជាប់នីមួយៗក៏ដោយ ដើម្បីបង្ការការកកស្ទះចរាចរសន្ទនា។ ប្រសិនបើពិនិត្យឃើញបមាណីទូរស័ព្ទ ( Switching ) មានមុខងារតភ្ជាប់នៅមានលទ្ធភាពផ្តល់សមត្ថភាពទៀត ក្រុមហ៊ុនផ្តល់ការតភ្ជាប់ត្រូវទទួលខុសត្រូវផ្តល់ជូនបន្ថែមក្នុងរយៈពេលយ៉ាងយូរ ១០ ថ្ងៃនៃថ្ងៃធ្វើការចាប់ពីពេលទទួលលិខិតស្នើសុំដែលស្របទៅនឹងប្រការទាំងឡាយមានចែងក្នុងកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ ហើយមានសិទ្ធិគិតចំណាយបន្ថែម។ កម្រិតអតិបរមានៃចំណាយបន្ថែមនេះ ពុំត្រូវលើសពី ពីរដងនៃថ្លៃជួលជាប្រចាំខែសម្រាប់ផ្លូវ E1 ក្នុងខេត្ត-ក្រុងទេ។

២) ក្នុងករណីមានការកកស្ទះចរាចរសន្ទនានៃការតភ្ជាប់ ហើយក្រុមហ៊ុនទាំងពីរមិនអាចព្រមព្រៀងគ្នាលើបញ្ហានានាដែលទាក់ទងនឹងការអនុវត្តការពង្រីកសមត្ថភាពតភ្ជាប់ដែលស្ថិតក្រៅផែនការខែ គិតតាមចំណុចនីមួយៗនោះទេ ត្រូវអនុវត្តវិធីដោះស្រាយតាមលំដាប់បែបបទ និង ពេលវេលាដូចតទៅ:

ក) ក្រុមហ៊ុនសុំការតភ្ជាប់ត្រូវធ្វើលិខិតផ្ញើមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និង ចម្លងជូនក្រុមហ៊ុនផ្តល់ការតភ្ជាប់។ លិខិតនេះត្រូវមានខ្លឹមសារដូចតទៅ:

- ទិន្នន័យបញ្ជាក់អំពីការកកស្ទះចរាចរសន្ទនា,
- មូលដ្ឋាននៃការគណនាការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់,

- កំណត់ថ្ងៃចាប់ផ្តើមពង្រីកបន្ថែមសមត្ថភាពតភ្ជាប់,
- សំណូមពរផ្សេងៗទាក់ទងនឹងការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់ជាយថាហេតុ។

ខ) ផ្អែកលើពាក្យស្នើសុំរបស់ក្រុមហ៊ុនសុំការតភ្ជាប់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវស្នើទៅក្រុមហ៊ុនផ្តល់ការតភ្ជាប់ឱ្យពាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធភាពឆ្លើយតបទៅនឹងការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់របស់ខ្លួនជាយថាហេតុតាមការស្នើនៃក្រុមហ៊ុនសុំការតភ្ជាប់។ ក្រុមហ៊ុនផ្តល់ការតភ្ជាប់ ត្រូវឆ្លើយតបតាមការស្នើ មិនឱ្យលើសពី ៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលទទួលលិខិតស្នើសុំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ លិខិតឆ្លើយតបត្រូវបញ្ជាក់អំពីព័ត៌មានដូចតទៅ :

- សមត្ថភាពដែលអាចផ្តល់ជូនតាមទិសដៅនីមួយៗ,
- កំណត់ថ្ងៃដែលចាប់ផ្តើមពង្រីកបន្ថែមសមត្ថភាពតភ្ជាប់,
- សំណូមពរផ្សេងៗទាក់ទងនឹងការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់ជាយថាហេតុ។

គ) ដោយឈរលើមូលដ្ឋាននៃរបាយការណ៍របស់ក្រុមហ៊ុនទាំងពីរ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងពិនិត្យវាយតម្លៃស្ថានភាពកកស្ទះចរាចរសន្ទនានៃការតភ្ជាប់នេះ។ ការវាយតម្លៃ នឹងអនុវត្តទៅតាមកម្រិតកំណត់ក្នុង ឧបសម្ព័ន្ធទី ១ និង លទ្ធភាពការតភ្ជាប់របស់បមាណីទូរស័ព្ទទៅតាមកម្រិតកំណត់ក្នុង ឧបសម្ព័ន្ធទី ២។ ក្នុងករណីមានការកកស្ទះចរាចរសន្ទនានៃការតភ្ជាប់ ហើយបមាណីទូរស័ព្ទនៅមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ផ្តល់សមត្ថភាពតភ្ជាប់បន្ថែមទៀត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងរៀបចំបែងចែកឡើងវិញនូវផ្លូវដែលនៅសល់សម្រាប់យកទៅបំពេញបន្ថែមសមត្ថភាពទៅតាមទិសដៅតភ្ជាប់ផ្សេងៗទៀត ដើម្បីធានាការប្រើប្រាស់ផ្លូវតភ្ជាប់ឱ្យមានប្រសិទ្ធភាព។

**ប្រការ ១៦ : ការធានាគុណភាពនៃការតភ្ជាប់បណ្តាញរវាងគ្នា**

១) គុណភាពនៃការតភ្ជាប់ផ្លូវប្រព័ន្ធ ត្រូវធានាឱ្យបានដូចគុណភាពនៃការតភ្ជាប់ផ្ទៃក្នុង និង គោរពតាមបទដ្ឋានស្តីពីគុណភាពសេវាក្នុងវិស័យទូរគមនាគមន៍។

២) នៅពេលអនុវត្ត ក្រុមហ៊ុនត្រូវទទួលខុសត្រូវលើកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ ដើម្បីធានាឱ្យបាននូវសមត្ថភាពតភ្ជាប់និងគុណភាពនៃការផ្តល់ស៊ីញ៉ាល់។

**ប្រការ ១៧ : ការរៀបចំរបាយការណ៍នៃការតភ្ជាប់បណ្តាញរវាងគ្នា**

១) ក្រុមហ៊ុនទូរគមនាគមន៍ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆ្នាំមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អំពីស្ថានភាពអនុវត្តកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់ តាមគំរូរបាយការណ៍ក្នុង ឧបសម្ព័ន្ធទី ៣។

២) នៅពេលមានការកកស្ទះចរាចរសន្ទនានៃការតភ្ជាប់ ក្រុមហ៊ុនទូរគមនាគមន៍ត្រូវធ្វើរបាយការណ៍អំពីស្ថានភាពតភ្ជាប់ទៅតាមទិសដៅដែលកកស្ទះចរាចរសន្ទនានោះមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍តាមគំរូក្នុង ឧបសម្ព័ន្ធទី ៤។

៣) ក្នុងករណីមានការស្នើពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រុមហ៊ុនទូរគមនាគមន៍ត្រូវផ្តល់របាយការណ៍អំពីស្ថានភាពនៃការតភ្ជាប់តាមទិសដៅដែលកកស្ទះចរាចរសន្ទនា ឬ នៅលើចំណុចតភ្ជាប់ដែលពាក់ព័ន្ធ និង ផ្តល់ទិន្នន័យផ្សេងៗដែលបានកត់ត្រាក្នុងបមាណីទូរស័ព្ទតភ្ជាប់ ដើម្បីបញ្ជាក់ឱ្យឃើញថា អាចកើតមានឡើងនូវការកកស្ទះចរាចរសន្ទនា។ ទម្រង់នៃរបាយការណ៍នៅពេលកកស្ទះចរាចរសន្ទនាកើតឡើងជាយថាហេតុរវាងចំណុចតភ្ជាប់ផ្ទាល់មានក្នុង ឧបសម្ព័ន្ធទី ៤។

៤) ក្រុមហ៊ុនទូរគមនាគមន៍ត្រូវទទួលខុសត្រូវលើខ្លឹមសារ ទិន្នន័យនៅក្នុងរបាយការណ៍និងត្រូវផ្តល់ឱ្យបានទាន់ពេលវេលា។ ក្នុងករណីចាំបាច់ ក្រុមហ៊ុនទូរគមនាគមន៍ ត្រូវបញ្ជាក់អំពីភាពត្រឹមត្រូវនៅក្នុងរបាយការណ៍។ នៅពេលមានការស្នើពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រុមហ៊ុនទូរគមនាគមន៍ត្រូវចាត់អ្នកបច្ចេកទេសសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ព្រមទាំងផ្តល់ឧបករណ៍ពិនិត្យទិន្នន័យក្នុងរបាយការណ៍របស់ក្រុមហ៊ុន។

- កំណត់ថ្ងៃចាប់ផ្តើមពង្រីកបន្ថែមសមត្ថភាពតភ្ជាប់,
- សំណូមពរផ្សេងៗទាក់ទងនឹងការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់ជាយថាហេតុ។

ខ) ផ្អែកលើពាក្យស្នើសុំរបស់ក្រុមហ៊ុនសុំការតភ្ជាប់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវស្នើទៅក្រុមហ៊ុនផ្តល់ការតភ្ជាប់ឱ្យរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធភាពឆ្លើយតបទៅនឹងការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់របស់ខ្លួនជាយថាហេតុតាមការស្នើនៃក្រុមហ៊ុនសុំការតភ្ជាប់។ ក្រុមហ៊ុនផ្តល់ការតភ្ជាប់ ត្រូវឆ្លើយតបតាមការស្នើ មិនឱ្យលើសពី ៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលទទួលលិខិតស្នើសុំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ លិខិតឆ្លើយតបត្រូវបញ្ជាក់អំពីព័ត៌មានដូចតទៅ:

- សមត្ថភាពដែលអាចផ្តល់ជូនតាមទិសដៅនីមួយៗ,
- កំណត់ថ្ងៃដែលចាប់ផ្តើមពង្រីកបន្ថែមសមត្ថភាពតភ្ជាប់,
- សំណូមពរផ្សេងៗទាក់ទងនឹងការពង្រីកបន្ថែមសមត្ថភាពតភ្ជាប់ជាយថាហេតុ។

គ) ដោយឈរលើមូលដ្ឋាននៃរបាយការណ៍របស់ក្រុមហ៊ុនទាំងពីរ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងពិនិត្យវាយតម្លៃស្ថានភាពកកស្ទះចរាចរសន្ទនានៃការតភ្ជាប់នេះ។ ការវាយតម្លៃ នឹងអនុវត្តទៅតាមកម្រិតកំណត់ក្នុង ឧបសម្ព័ន្ធទី ១ និង លទ្ធភាពការតភ្ជាប់របស់បមាណីទូរស័ព្ទទៅតាមកម្រិតកំណត់ក្នុង ឧបសម្ព័ន្ធទី ២។ ក្នុងករណីមានការកកស្ទះចរាចរសន្ទនានៃការតភ្ជាប់ ហើយបមាណីទូរស័ព្ទនៅមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ផ្តល់សមត្ថភាពតភ្ជាប់បន្ថែមទៀត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងរៀបចំបែងចែកឡើងវិញនូវផ្លូវដែលនៅសល់សម្រាប់យកទៅបំពេញបន្ថែមសមត្ថភាពទៅតាមទិសដៅតភ្ជាប់ផ្សេងៗទៀត ដើម្បីធានាការប្រើប្រាស់ផ្លូវតភ្ជាប់ឱ្យមានប្រសិទ្ធភាព។

## ប្រការ ១៦ : ការធានាគុណភាពនៃការតភ្ជាប់បណ្ដាញរវាងគ្នា

១ ) គុណភាពនៃការតភ្ជាប់ឆ្លងប្រព័ន្ធ ត្រូវធានាឱ្យបានដូចគុណភាពនៃការតភ្ជាប់ផ្ទៃក្នុង និង គោរពតាមបទដ្ឋានស្ដីពីគុណភាពសេវាក្នុងវិស័យទូរគមនាគមន៍។

២ ) នៅពេលអនុវត្ត ក្រុមហ៊ុនត្រូវទទួលខុសត្រូវលើកិច្ចសន្យាស្ដីពីការផ្ដល់សមត្ថភាពតភ្ជាប់ ដើម្បីធានាឱ្យបាននូវសមត្ថភាពតភ្ជាប់និងគុណភាពនៃការផ្ដល់ស៊ីញ៉ាល់។

## ប្រការ ១៧ : ការរៀបចំរបាយការណ៍នៃការតភ្ជាប់បណ្ដាញរវាងគ្នា

១ ) ក្រុមហ៊ុនទូរគមនាគមន៍ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆ្នាំមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អំពីស្ថានភាពអនុវត្តកិច្ចសន្យាស្ដីពីការផ្ដល់សមត្ថភាពតភ្ជាប់ តាមគំរូរបាយការណ៍ក្នុង ឧបសម្ព័ន្ធទី ៣។

២ ) នៅពេលមានការកកស្ទះចរាចរសន្ទនានៃការតភ្ជាប់ ក្រុមហ៊ុនទូរគមនា-គមន៍ត្រូវធ្វើរបាយការណ៍អំពីស្ថានភាពតភ្ជាប់ទៅតាមទិសដៅដែលកកស្ទះចរាចរសន្ទនានោះមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍តាមគំរូក្នុង ឧបសម្ព័ន្ធទី ៤។

៣ ) ក្នុងករណីមានការស្នើពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រុមហ៊ុនទូរគមនាគមន៍ត្រូវផ្ដល់របាយការណ៍អំពីស្ថានភាពនៃការតភ្ជាប់តាមទិសដៅដែលកកស្ទះចរាចរសន្ទនា ឬ នៅលើចំណុចតភ្ជាប់ដែលពាក់ព័ន្ធ និង ផ្ដល់ទិន្នន័យផ្សេងៗដែលបានកត់ត្រាក្នុងបមាណីទូរស័ព្ទតភ្ជាប់ ដើម្បីបញ្ជាក់ឱ្យឃើញថា អាចកើតមានឡើងនូវការកកស្ទះចរាចរសន្ទនា។ ទម្រង់នៃរបាយការណ៍នៅពេលកកស្ទះចរាចរសន្ទនាកើតឡើងដោយថាហេតុរវាងចំណុចតភ្ជាប់ផ្ទាល់មានក្នុង ឧបសម្ព័ន្ធទី ៤។

៤ ) ក្រុមហ៊ុនទូរគមនាគមន៍ត្រូវទទួលខុសត្រូវលើខ្លឹមសារ ទិន្នន័យនៅក្នុងរបាយការណ៍និងត្រូវផ្ដល់ឱ្យបានទាន់ពេលវេលា។ ក្នុងករណីចាំបាច់ ក្រុមហ៊ុនទូរគមនាគមន៍ ត្រូវបញ្ជាក់អំពីភាពត្រឹមត្រូវនៅក្នុងរបាយការណ៍។ នៅពេលមានការស្នើពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រុមហ៊ុនទូរគមនាគមន៍ត្រូវចាត់អ្នកបច្ចេកទេសសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ព្រមទាំងផ្ដល់ឧបករណ៍ពិនិត្យទិន្នន័យក្នុងរបាយការណ៍របស់ក្រុមហ៊ុន។

**ប្រការ ១៨** : - ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

- រាល់ប្រកាស និង លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩** : ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ គ្រប់នាយកដ្ឋាន គ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត-ក្រុង និងអង្គភាពពាក់ព័ន្ធនានា ព្រមទាំងអគ្គនាយក នាយកនៃក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព។ ៕

រាជធានីភ្នំពេញ, ថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩

**រដ្ឋមន្ត្រី**

**សូ ខុន**

**កន្លែងទទួល** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងផែនការ

« ដើម្បីជូនជ្រាប »

- ដូចប្រការ ១៩
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១

# ការស្ទះចរាចរសន្ទនា នីតិវិធីនិងការអនុវត្ត

(ភ្ជាប់ជាមួយប្រកាសលេខ ២០៦ បទ.ប្រក ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩ ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍)

## ១) ការកំណត់ការកកស្ទះចរាចរសន្ទនា

$T_{AVERAGE}$ = ចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូល / ចរាចរសន្ទនាអនុញ្ញាតលើផ្លូវតភ្ជាប់ជាឯកទិសដោយៈ

ក) $T_{AVR} < 1$ ពុំទាន់មានការកកស្ទះ,

ខ) $T_{AVR} \geq 1$ ទិសដៅនេះមានការកកស្ទះ,

គ) $T_{AVR} \geq 0.9$ ជាកម្រិតមួយដែលចាំបាច់ត្រូវពង្រីកសមត្ថភាពតភ្ជាប់។

ក្នុងនោះ ៖

- ម៉ោងកំពូល (Peak-Hour) គឺជាចន្លោះពេលវេលាមួយម៉ោងដែលយកតាមស្ថិតិនៃការសន្ទនាមានកម្រិតខ្ពស់បំផុតក្នុងថ្ងៃ។
- ចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូល គឺជាតម្លៃមធ្យមនៃចរាចរសន្ទនានៅម៉ោងកំពូល ត្រូវគិតតាមខ្នាត Erlang ក្នុងច្រើនថ្ងៃ។
- ចរាចរសន្ទនាដែលអនុញ្ញាត គឺជាការសន្ទនាគិតតាមខ្នាត Erlang ស្របទៅនឹងចំនួនបរិបថត្រូវការតភ្ជាប់ ហើយខ្នាតនៃសេវាកម្ម គិតទៅតាមរូបមន្ត Erlang B (GoS=1%)។

## ២) វិធីអនុវត្ត

ក) ផ្អែកលើសមត្ថភាពចរាចរនៃការសន្ទនាជាក់ស្តែង ដែលកត់ត្រាបានក្នុងបមាណិទូរស័ព្ទ (Switching) មជ្ឈមណ្ឌលប្រតិបត្តិ និង ថែទាំ (OMC) ឬ ក៏នៅក្នុងកាលប្បវត្តិ។

ខ) ប្រើប្រាស់បរិក្ខារផ្តល់សញ្ញា (Signaling) វាស់ ដើម្បីតាមដានមើលចរាចរនៃការសន្ទនា។

## ៣ ) នីតិវិធី និង កម្រិតកំណត់

ក ) ពិនិត្យមើលចរាចរសន្ទនា ២៤ ម៉ោងក្នុង ១ ថ្ងៃ ក្នុងរយៈពេល ១ សប្តាហ៍ ផ្តើមពីនេះ ដើម្បីឃើញចរាចរសន្ទនានៅម៉ោងកំពូលក្នុងថ្ងៃតាមទិសដៅតភ្ជាប់នីមួយៗ។

ខ ) រកចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូលនៃផ្លូវឯកទិសក្នុងរយៈពេលពីរសប្តាហ៍ ( លើកលែងតែថ្ងៃសៅរ៍ អាទិត្យ និង ថ្ងៃបុណ្យទាន )។ រូបមន្តគិតគឺ៖

$T_{AVR}$ = ចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូល / ចរាចរសន្ទនាអនុញ្ញាត។

- កម្រិតកំណត់ : $0,8 \leq T_{AVR} < 0,9$ ក្រុមហ៊ុនពីរចូលរួមការតភ្ជាប់ ត្រូវធ្វើសេចក្តីជូនដំណឹងទៅវិញទៅមក ដើម្បីត្រៀមរៀបចំពង្រីកសមត្ថភាពបន្ថែមលើទិសដៅនេះ។
- កម្រិតកំណត់ : $T_{AVR} \geq 0,9$ ផ្តើមចេញពីចរាចរសន្ទនាជាក់ស្តែងលើទិសដៅតភ្ជាប់មានចរាចរសន្ទនានៅម៉ោងកំពូល ក្នុងរយៈពេលពីរសប្តាហ៍ ( លើកលែងតែថ្ងៃមានព្រឹត្តិការណ៍ពិសេស ដែលចរាចរកើនឡើងដោយគំហុក ) ត្រូវគណនាទៅតាមរូបមន្ត Erlang B ( ឬ រកក្នុងតារាង GoS=1% ) ដើម្បីរកចំនួនបរិបថ ។ ពីចំនួននេះ រកឃើញចំនួនផ្លូវ E1 ហើយប្រៀបធៀបទៅនឹងចំនួនផ្លូវ E1 ជាក់ស្តែង ដើម្បីគណនាចំនួនផ្លូវ E1 ដែលត្រូវបន្ថែម។

ក្នុងនោះ៖

+ ចរាចរជាក់ស្តែងជាចរាចរនៃការសន្ទនាគិតតាមខ្នាត Erlang ឆ្លងកាត់ចំណុចតភ្ជាប់ទៅលើទិសដៅនីមួយៗ ។
+ ខ្នាតនៃសេវាកម្ម ( GoS ) ជា Probability គណនាតាមអត្រាការហៅ និងការកកស្ទះចរាចរសន្ទនានៅក្នុងប្រព័ន្ធនៅម៉ោងកំពូល។

# ឧបសម្ព័ន្ធទី ២

# ប្រសិទ្ធភាពនៃការប្រើប្រាស់ និតិវិធីគណនាលទ្ធភាពបមាណីទូរស័ព្ទ និងផែនការបន្ថែមពីផ្លូវដែលលើសល់

( ភ្ជាប់ជាមួយប្រកាសលេខ ២០៦ បទ.ប្រក ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩
ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍ )

**១ ) កម្រិតកំណត់ប្រសិទ្ធភាពនៃការប្រើប្រាស់**

$T_{AVR}$ = ចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូល / ចរាចរសន្ទនាអនុញ្ញាតនៃផ្លូវតភ្ជាប់ជាឯកទិស ដោយៈ

ក ) កម្រិតកំណត់ : $T_{AVR} \geq 0,6$ ការប្រើប្រាស់មានប្រសិទ្ធភាព។

ខ ) កម្រិតកំណត់ : $T_{AVR} < 0,6$ ការប្រើប្រាស់ពុំមានប្រសិទ្ធភាព។

ក្នុងនោះ ៖

- ម៉ោងកំពូល ( Peak-Hour ) គឺជាចន្លោះពេលវេលាមួយម៉ោង ដែលយកតាមស្ថិតិចរាចរសន្ទនាមានកម្រិតខ្ពស់បំផុតក្នុងថ្ងៃ។
- ចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូល គឺជាតម្លៃមធ្យមនៃចរាចរសន្ទនានៅម៉ោងកំពូល ត្រូវគិតតាមខ្នាត Erlang ក្នុងច្រើនថ្ងៃ ។
- ចរាចរសន្ទនាដែលអនុញ្ញាត ជាការសន្ទនាគិតតាមខ្នាត Erlang ស្របទៅនឹងចំនួនបរិបថត្រូវការតភ្ជាប់ ហើយខ្នាតនៃសេវាកម្មគិតទៅតាមរូបមន្ត Erlang B ( GoS=1% )។

**២ ) វិធីអនុវត្ត**

ក ) ផ្អែកលើសមត្ថភាពចរាចរនៃការសន្ទនាជាក់ស្តែង ដែលកត់ត្រាបានក្នុងបមាណីទូរស័ព្ទ ( Switching ) មជ្ឈមណ្ឌលប្រតិបត្តិ និង ថែទាំ ( OMC )ឬក៏នៅក្នុងកាលប្បវត្តិ។

ខ ) ផ្អែកលើការអភិវឌ្ឍជាក់ស្តែងលើសមត្ថភាពបណ្តាញ និងចរាចរសន្ទនានៃការតភ្ជាប់ផ្ទៃក្នុង។

គ ) ប្រើប្រាស់បរិក្ខារផ្តល់សញ្ញា ( Signaling ) វាស់ដើម្បីតាមដានមើលចរាចរនៃការសន្ទនា។

## ៣ ) វិធីសាស្ត្រ និង កម្រិតកំណត់

ក ) ពិនិត្យមើលចរាចរសន្ទនា ២៤ ម៉ោងក្នុង ១ ថ្ងៃក្នុងរយៈពេល ១ សប្តាហ៍ ផ្តើមចេញពីនេះ នេះនឹងឃើញចរាចរសន្ទនានៅម៉ោងកំពូលក្នុងថ្ងៃ តាមទិសដៅតភ្ជាប់នីមួយៗ។

ខ ) ការរកចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូលលើឯកទិសក្នុងរយៈពេលបួនសប្តាហ៍ ( លើកលែងតែថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យ )។ រូបមន្តគិត :

$T_{AVR}$ = ចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូល / ចរាចរអនុញ្ញាតផ្លូវឯកទិស។

- កម្រិតកំណត់ : $T_{AVR} \geq 0.6$ មិនចាំបាច់បន្ថយសមត្ថភាពតភ្ជាប់លើទិសដៅនេះទេ។
- កម្រិតកំណត់ : $T_{AVR} < 0,6$ ប្រសិនបើទិសដៅនេះមានផ្លូវ E1 ច្រើនជាងមួយ នឹងត្រូវគណនាចំនួនផ្លូវនៅសល់ ដែលអាចយកទៅពង្រីកបន្ថែមសមត្ថភាពតភ្ជាប់លើទិសដៅផ្សេងៗតាមគោលការណ៍ធានាការប្រើប្រាស់ឱ្យមានប្រសិទ្ធភាព។
- ដើម្បីកំណត់បាននូវចំនួនផ្លូវ E1 នៅសល់ ដែលភាគីសុំតភ្ជាប់ត្រូវបង់ថ្លៃជួលជាវបន្ថែម : យកពីចរាចរសន្ទនាជាមធ្យមនៅម៉ោងកំពូល ក្រោយពីចែកនឹង 0,6 ហើយគិតទៅតាមរូបមន្ត Erlang B ( ឬ រកក្នុងតារាង GoS=1% ) ដើម្បីរកចំនួនបរិបថ។ ពីនោះឃើញចំនួនផ្លូវ E1 ហើយប្រៀបទៅនឹងចំនួនផ្លូវ E1 ជាក់ស្តែង ដើម្បីគណនាចំនួនផ្លូវ E1 នៅសល់។



# ឧបសម្ព័ន្ធទី ៣

# គំរូរបាយការណ៍ប្រចាំត្រីមាស និង ប្រចាំឆ្នាំ

# ស្តីពីស្ថានភាពអនុវត្តកិច្ចសន្យាតភ្ជាប់រវាងក្រុមហ៊ុនផ្សេងៗ

( ភ្ជាប់ជាមួយប្រកាសលេខ ២០៦ បទ.ប្រក ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩
ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍ )

**១ ) គំរូរបាយការណ៍**

ឈ្មោះក្រុមហ៊ុន : ... ... ... ... ... ... ... ... ... ... ...

**របាយការណ៍**

**ស្តីពី**

**ស្ថានភាពអនុវត្តកិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់**
**ជាមួយក្រុមហ៊ុនទូរគមនាគមន៍ផ្សេងៗ**

ក ) កិច្ចសន្យាក្នុងការតភ្ជាប់

| ល.រ. | កាលបរិច្ឆេទ | ក្រុមហ៊ុនជាដៃគូ | សុពលភាព | ស្ថានភាពចុះកិច្ចសន្យា | | កំណត់សម្គាល់ |
|---|---|---|---|---|---|---|
| | | | | មាន | គ្មាន | |
| ១ | | | | | | |
| ២ | | | | | | |
| **សរុប** | | | | | | |

**សម្គាល់** : ក្នុងករណីមានកិច្ចព្រមព្រៀងដោយឡែកផ្សេងទៀត ក្រុមហ៊ុនត្រូវបំពេញតួលេខដោយបង្កើតតារាងបន្ថែមៗ

ខ) ស្ថានភាពអនុវត្តកិច្ចសន្យា

| ល.រ. | ក្រុមហ៊ុនជាដៃគូ | ចំនួន EI | | ចំនួន EI កែប្រែ | | | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|
| | | ផែនការ | ចំនួន EI បច្ចុប្បន្ន | បន្ថែម | បន្ថយ | មូលហេតុ | |
| ១ | | | | | | | |
| ២ | | | | | | | |
| - | | | | | | | |
| - | | | | | | | |
| - | | | | | | | |

**សម្គាល់** : តួលេខដែលមាននៅក្នុងជួរបញ្ឈរ ( Column ) ផ្នែកកំណត់សម្គាល់ត្រូវដូចគ្នានឹងរបាយការណ៍ប្រចាំត្រីមាស និង ឆ្នាំ។

គ) សំណូមពរ

**២) កាលបរិច្ឆេទនៃការផ្ញើរបាយការណ៍**

ក) ចំពោះរបាយការណ៍ត្រីមាសនីមួយៗ ត្រូវផ្ញើឱ្យបានមុនថ្ងៃទី ១០ ក្នុងខែដំបូងនៃត្រីមាសបន្ទាប់។

ខ) ចំពោះរបាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើឱ្យបានមុនថ្ងៃទី ១៥ ក្នុងខែមករានៃឆ្នាំបន្ទាប់។

# ឧបសម្ព័ន្ធទី ៤

# គំរូរបាយការណ៍ស្ដីពី

# ការស្ទះចរាចរសន្ទនាដែលកើតឡើងដោយជាហេតុ

# រវាងក្រុមហ៊ុនជាដៃគូ

( ភ្ជាប់ជាមួយប្រកាសលេខ ២០៦ បទ.ប្រក ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩

ស្ដីអំពីការតភ្ជាប់បណ្ដាញទូរគមនាគមន៍ )

ឈ្មោះក្រុមហ៊ុន : ... ... ... ... ... ... ... ... ... ...

| ល.រ. | ទិសដៅភ្ជាប់បណ្ដាញ | ផ្លូវកកស្ទះ ចេញ / ចូល (OG/IC) | ពេលកកស្ទះ (ម៉ោង) | ថ្ងៃខែឆ្នាំ | ចំនួន E1 បច្ចុប្បន្ន | ចំនួនបរិបថបច្ចុប្បន្ន | ស្ថានភាពកកស្ទះជា Erlang (Erl) | | | ចំនួន E1 ត្រូវមាន | ចំនួន E1 ត្រូវបន្ថែម |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | អនុញ្ញាត (GoS=1%) | ជាក់ស្ដែង | អត្រា ជាក់ស្ដែង / អនុញ្ញាត | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

**កំណត់សម្គាល់ :** របាយការណ៍ត្រូវធ្វើដោយលម្អិតទៅតាមថ្ងៃនីមួយៗយ៉ាងតិចក្នុងរយៈពេលពីរសប្ដាហ៍ នឹងត្រូវពង្រីកបន្ថែមសមត្ថភាពតភ្ជាប់បណ្ដាញ :

- ផែនការនិងថ្ងៃកំណត់ពង្រីកសមត្ថភាព.
- សំណូមពរផ្សេងៗទាក់ទងនឹងការពង្រីកបន្ថែមសមត្ថភាពដែលកើតឡើងដោយជាហេតុ។
- សំណូមពរផ្សេងៗទៀត៕

# ឧបសម្ព័ន្ធទី ៤

# វិធីសាស្ត្រគណនាសមត្ថភាពសរុបនៃការតភ្ជាប់បណ្ដាញ

( ភ្ជាប់ជាមួយប្រកាសលេខ ២០៦ បទ.ប្រក ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩
ស្ដីអំពីការតភ្ជាប់បណ្ដាញទូរគមនាគមន៍ )

## ១ ) ការកំណត់បទដ្ឋានមួយចំនួនសម្រាប់គណនា

- ខ្នាតនៃសេវាកម្ម Grade of Service GoS =1%,
- ចរាចរសន្ទនាជាមធ្យមរបស់ទូរស័ព្ទជួលជាវក្នុងមួយគ្រឿងគឺ $E_{AVR}$ = 0,01 Erlang។ ( Average Traffic per Subscriber $E_{AVR}$ = 0,01E )។
- ការប៉ាន់ស្មានចំនួនជួលជាវទូរស័ព្ទសរុបរបស់ក្រុមហ៊ុនក្នុងឆ្នាំ ( Estimate Total Subscriber Numbers in Year TSN ) TSN ក្នុងនោះ៖
  - ◎ TSN (A) គឺជាចំនួនជួលជាវទូរស័ព្ទសរុបរបស់ក្រុមហ៊ុនសុំការតភ្ជាប់ « ក »។
  - ◎ TSN (B) គឺជាចំនួនជួលជាវទូរស័ព្ទសរុបរបស់ក្រុមហ៊ុនផ្ដល់ការតភ្ជាប់ « ខ »។
  - ◎ GTSN ( Σ ) = TSN ( A ) + TSN ( B ) គឺជាចំនួនជួលជាវទូរស័ព្ទសរុបរបស់ក្រុមហ៊ុនសុំ « ក » TSN ( A ) និង សាជីវកម្មផ្ដល់ការតភ្ជាប់ « ខ » TSN ( B )។
- សមត្ថភាពសរុបរបស់អ្នកជួលជាវទូរស័ព្ទនៃប្រព័ន្ធ « ក » ហៅទៅអ្នកជួលជាវទូរស័ព្ទនៃប្រព័ន្ធ « ខ » ( Total Traffic on Outgoing from network A to network B is $O/G_{AB}$ )។
- ចរាចរសន្ទនាសរុបរបស់អ្នកជួលជាវទូរស័ព្ទនៃប្រព័ន្ធ « ខ » ហៅទៅអ្នកជួលជាវទូរស័ព្ទនៃប្រព័ន្ធ « ក » ( Total Traffic on Outgoing from network B to network A $O/G_{BA}$ )។
- ចរាចរសន្ទនាសរុបរវាងបណ្ដាញទាំងពីរ « ក » - « ខ » កំណត់ជា Total Outgoing Traffic ( TOT )
- ចំនួនបរិបថសន្ទនា គិតតាមតារាង Erlang B ដោយដឹងពី TOT និង GoS=1% គឺ $CN_{\text{Erlang Table}}$ ។
- ចំនួនផ្លូវ E1 ត្រូវការ ( Total Trunk Numbers ) TTN គឺគណនាជាចំនួនបរិបថសន្ទនាតាមតារាង Erlang នៅខាងលើ CN / 30។

## ២ ) វិធីសាស្ត្រគណនាសមត្ថភាពតភ្ជាប់សរុបឆ្លងទៅកាន់បណ្តាញផ្សេងៗ

រូបមន្ត :

- $TOT_{AB} = TSN(A) * E_{AVR} * (TSN(B) / TSN(\Sigma))$;
- $TOT_{BA} = TSN(B) * E_{AVR} * (TSN(A) / TSN(\Sigma))$;
- $TOT = TOT_{AB} = TOT_{BA} = E_{AVR} * (TSN(B) * TSN(A) / TSN(\Sigma))$;
- មើលក្នុងតារាងដោយដឹង TOT និង GoS = 1% រកឃើញ $CN_{Erlang\ Table}$ ជាចំនួនផ្លូវសន្ទនា ហៅថា ចំនួនបរិបថ ( Circuits Number: CN )។
- Trunk Number (ចំនួនផ្លូវ E1 ) $TN = CN_{Erlang\ Table} / 30$។